# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Oct-22, 15:51
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់បំផុត**
**(សាធារណៈ: សម្រាប់ឯកសារកោសលុប)**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សំណើសុំទទួលបានពតិមានពីសហព្រះរាជអាជ្ញា អំពីលក្ខខណ្ឌនៃការឃុំខ្លួន
លោក ខៀវ សំផន ក្រោយពីមានការចេញសាលដីកាមានសំអាងហេតុពេញលេញ
លើសំណុំរឿង ០០២/០២**

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះតុលាការកំពូល៖** |
| មេធាវី គង់ សំអុន | ចៅក្រម គង់ ស្រ៊ីម |
| មេធាវី Anta GUISSÉ | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម សោម សិរីវឌ្ឍ |

**ជំនួយការ៖**

លោកស្រី សេង សុជាតា

ចៅក្រម Florence Ndepele MWACHANDE-MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Phillip RAPOZA

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Fergal GAYNOR

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ (សម្រាប់តែឯកសារកោសលុបដែលបានដាក់ជាសាធារណៈ តែប៉ុណ្ណោះ)**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានចេញសេចក្តីសង្ខេបលើសាលដីការបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ ("សង្ខេបសាលដីកា") ដែលក្នុងនោះ តុលាការកំពូលបានសម្រេចតម្កល់ការដាក់ពិរុទ្ធភាពលើលោក ខៀវ សំផន ជាអតិបរមា ដែលបានសម្រេចក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានធ្វើកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។[1] នៅក្នុងសង្ខេបសាលដីកានេះ តុលាការកំពូលបានសម្រេច "បង្គាប់ថា ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក រង់ចាំការចេញសាលដីកាមានសំអាងហេតុពេញលេញ និងបញ្ចប់នូវការរៀបចំសម្រាប់ការផ្ទេរដោយអនុលោមតាមច្បាប់ទៅពន្ធនាគារដែលគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់"។[2]

២. តាមរយៈសំណោរនេះ សហមេធាវីការពារក្តី ខៀវ សំផន សូមតុលាការកំពូល មេត្តាបង្គាប់សួរទៅសហព្រះរាជអាជ្ញាថា ដោយអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការកំពូលនេះ តើលក្ខខណ្ឌឃុំខ្លួនលោក ខៀវ សំផន នឹងមានធ្វីខ្លះ។ ពីព្រោះថា តាមរយៈសង្ខេបសាលដីកាដែលតុលាការកំពូលខ្លួនឯងបានចាត់ទុកថា ខ្លួននៅតែបន្តមានសមត្ថកិច្ចលើសំណុំរឿងនេះ ក្នុងអម្លុងពេលគាត់តែងសាលដីកាមានសំអាងហេតុពេញលេញ បន្ថែមពីលើការដែលថា ខ្លួនស្ថិតនៅក្នុងទីតាំងមួយដែលអាចចាត់វិធានការទាំងឡាយ ដើម្បីធានាឲ្យមានការអនុវត្តតាមសេចក្តីសម្រេចរបស់ខ្លួនដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិអន្តរជាតិ (I)។ ដោយមានការបារម្ភស្របច្បាប់អំពីលក្ខខណ្ឌឃុំខ្លួនលោក ខៀវ សំផន នាពេលខាងមុខនេះ ដោយពិចារណាលើស្ថានភាពឃុំខ្លួនជាទូទៅនៅកម្ពុជា (II) វាជាការសំខាន់ដែលទាំងសហព្រះរាជអាជ្ញាជាតិ ក៏ដូចជាសហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើការបញ្ជាក់ជាផ្លូវការ និងជាសាធារណៈ ដល់តុលាការកំពូល ថា តើមានការរៀបចំអ្វីខ្លះសម្រាប់ការផ្ទេរលោក ខៀវ សំផន ហើយតើគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់ក្នុងលក្ខខណ្ឌពិតប្រាកដបែបណាខ្លះ ដោយពិចារណាលើអាយុ និងស្ថានភាពសុខភាពរបស់គាត់ (III)។

---

[1] សេចក្តីសង្ខេបសាលក្រមធ្វើក្នុងសវនាការថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារតុលាការ **E1/529.1**, សាលក្រមមានសេចក្តីសំអាងហេតុពេញលេញ៖ សាលក្រមសំណុំរឿង ០០២/០២ ជូនដំណឹងដល់ភាគីថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៩ ឯកសារតុលាការ **E465**។

[2] សេចក្តីសង្ខេបនៃសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារតុលាការ **F76.1** ផ្នែកសម្រេចសេចក្តី ទំព័រ៤៥។

៣. ក្នុងពេលធ្វើសន្និសីទកាសែតបន្ទាប់ពីអានសង្ខេបសាលដីកា សហមេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងថា សហព្រះរាជអាជ្ញាកំពុងដំណើរការស្វែងរកកន្លែងឃុំខ្លួនសមរម្យសម្រាប់លោក ខៀវ សំផន។ ដូច្នេះ សំណោរមួយនេះត្រូវចាត់ទុកជាបំណងប្រាថ្នាមួយដើម្បីគាំទ្រដំណើរការនេះ ក្នុងគោលបំណងតម្លាភាព និងការធានាសិទ្ធិលោក ខៀវ សំផន។

៤. ដោយហេតុថា សំណើមួយនេះមានបញ្ចូលនូវព័ត៌មានស្ថានភាពសុខភាពលោក ខៀវ សំផន សំណើនេះត្រូវបានដាក់ជាប្រភេទឯកសារសំងាត់បំផុត។ ដោយឡែក ក្នុងថ្ងៃដដែលនេះ ក៏មានដាក់ឯកសារជាប្រភេទសាធារណៈ និងកោសលុប។

## I. **តុលាការកំពូលជាអ្នកធានាការអនុវត្តច្បាប់អំពីការអនុវត្តទោស**

### **ក. អំពីច្បាប់អនុវត្តសម្រាប់ការអនុវត្តទោស**

៥. គឺសហព្រះរាជអាជ្ញាជាអ្នកធ្វើការអនុវត្តទោស អនុលោមតាមវិធាន១១៣ នៃវិធានផ្ទៃក្នុង (“វិធានផ្ទៃក្នុង”) ដែលចែងថា៖

១. ការអនុវត្តទោសត្រូវធ្វើតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា។ ការអនុវត្តសំណងដែលអនុលោមតាមវិធាន ២៣ ស្ទួនបួន (៣) (ក) ត្រូវធ្វើឡើងដោយអាជ្ញាធរជាតិដែលមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់កម្ពុជា តាមការផ្តួចផ្តើមគំនិតរបស់សមាជិកណាម្នាក់នៃក្រុមសមូហភាព លើកលែងតែសាលក្រមបញ្ជាក់ច្បាស់លាស់ថា សំណងនេះត្រូវផ្តល់ទៅឱ្យក្រុមមួយជាក់លាក់។ ក្នុងករណីបែបនេះ សមាជិកណាម្នាក់នៃក្រុមនោះ ត្រូវផ្តួចផ្តើមគំនិតការអនុវត្តសំណងនោះជំនួសវិញ។ ការអនុវត្តសំណងដែលមានចែងក្នុងវិធាន២៣ *ស្ទួនបួន* (៣) (ខ) មិនស្ថិតនៅក្រោមវិសាលភាពនៃវិធាននេះទេ។

២. សហព្រះរាជអាជ្ញាធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានចូលជាស្ថាពរ លើកលែងតែបទប្បញ្ញត្តិទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

៦. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ (« ក្រមនីតិវិធីព្រហ្មទណ្ឌ ») មានចែងនូវបទបញ្ញត្តិជាច្រើនទាក់ទងនឹងការឃុំខ្លួន ជាពិសេសបទបញ្ញត្តិខាងក្រោមនេះ៖

“**មាត្រា ៤៩៦ កថាខណ្ឌ១**

ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ។

**មាត្រា ៤៩៧ កថាខណ្ឌ១**

អយ្យការធ្វើការអនុវត្តទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយទៅជាស្ថាពរ

**មាត្រា ៥០០ កថាខណ្ឌ១**

ការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬ តុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្តន្ទាទោសនោះ ដោះស្រាយ។”[3]

៧. ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[4] បានចែងដូចខាងក្រោម៖

**មាត្រា២**

ច្បាប់នេះមានគោលដៅដូចតទៅ៖

- អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី
- គ្រប់គ្រងជនជាប់ឃុំអោយធានាបានសន្តិសុខ សុវត្ថិភាព សុខភាព និងមនុស្សធម៌ ស្របតាមគោលការណ៍អន្តរជាតិ និងវិធានសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលតម្រូវបានដកហូតសិទ្ធិសេរីភាព។

**មាត្រា៣៨**

ជនជាប់ឃុំដែលមានជំងឺត្រូវបានទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ។ ជនជាប់ឃុំមានជំងឺធ្ងន់ ហើយតម្រូវអោយមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដេលតម្រូវអោយមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់ តាមសំណុំរបស់មន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត

---

[3] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[4] ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១ ប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២១១/០២១។

តាមសំណើរបស់ជនជាប់ឃុំ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាលត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ។
ជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក។

សូមលើកឡើងដែរថា បើទោះជាច្បាប់នេះហាក់ដូចជាសង្កត់ធ្ងន់លើការការពារដល់ជនជាប់ឃុំអនីតិជន តែមិនឃើញឃើញមានការចែងជាក់លាក់សម្រាប់មនុស្សចាស់ឡើយ។[5]

៨. បើពិនិត្យមើលបទបញ្ញត្តិអន្តរជាតិវិញ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ ១៩៩២ បានចែងដូចខាងក្រោម៖

**មាត្រា៧**

គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ដែលឃោរឃៅអមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។ (...)

**មាត្រា១០**

១- ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមនុស្សធម៌ និងការគោរពចំពោះសេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស។ (...)

៩. ក្នុងនាមជាតុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិ អ.វ.ត.ក ក៏ត្រូវគិតគូរផងដែរដល់ឧត្តមានុវត្ត ដូចមានចែងក្នុងវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ដែលត្រូវបានគេស្គាល់ថាជាវិធាន នែលសាន់ ម៉ាន់ដឺឡា ("វិធាន នែលសាន់ ម៉ាន់ដឺឡា")[6]។ ប្រការដំបូងៗនៃវិធាន នែលសុន ម៉ង់ដឺឡា ចែងលម្អិតអំពីគោលការណ៍ជាមូលដ្ឋានដែលគ្រប់គ្រងលើការឃុំឃាំង ដូចខាងក្រោម៖

**គោលការណ៍ជាមូលដ្ឋាន**

**វិធាន ១៖**

---

[5] មានតែក្នុងកម្រងឯកសារនីតិវិធីពន្ធនាគារ ឆ្នាំ ២០០៣ ប៉ុណ្ណោះដែលមានកំណត់ខ្លះៗអំពីអ្នកទោសចាស់ជរា៖ នីតិវិធីលេខ ១១ ចំណុច៣-២ ថាអ្នកទោសដែលមានរបួសឬជំងឺ និងអ្នកទោសដែលមានវ័យចាស់ជរាត្រូវបានលើកលែងពីការងារពន្ធនាគារ។

[6] វិធានអនុម័តជាឯកច្ឆន្ទដោយសេចក្តីសម្រេចលេខ ៧០/១៧៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១៥។

សេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្សជាតិរបស់ជនជាប់ឃុំទាំងអស់ គួរត្រូវបានគោរព។ គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានបង្ខំឲ្យទទួលរងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្មផ្សេងទៀត ហើយជនជាប់ឃុំទាំងអស់ត្រូវបានការពារពីអំពើទាំងនេះ ទោះជាក្នុងហេតុផល ឬកាលៈទេសៈបែបណាក៏ដោយ។ សុវត្ថិភាព និងសន្តិសុខរបស់ជនជាប់ឃុំ បុគ្គលិក អ្នកផ្តល់សេវា និងអ្នកសួរសុខទុក្ខ ត្រូវបានធានាគ្រប់ពេល។

**វិធាន ២៖**

១. បទប្បញ្ញត្តិដូចតទៅនេះត្រូវយកទៅអនុវត្ត ដោយមិនឲ្យមានលម្អៀងឡើយ។ មិនត្រូវមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិដទៃៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃៗទៀតឡើយ។ ត្រូវគោរពជំនឿសាសនា និងសីលធម៌របស់ជនជាប់ឃុំ។

២. ដើម្បីដាក់ឲ្យអនុវត្តគោលការណ៍មិនរើសអើង **រដ្ឋបាលពន្ធនាគារត្រូវគិតគូរពីសេចក្តីត្រូវការរបស់ជនជាប់ឃុំម្នាក់ៗ ជាពិសេស ក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងពន្ធនាគារ**។ ត្រូវចាត់វិធានការការពារ និងលើកកម្ពស់សិទ្ធិជនជាប់ឃុំដែលមានសេចក្តីត្រូវការពិសេស ហើយមិនត្រូវបានចាត់ទុកជាការរើសអើងឡើយ។ *(យើងខ្ញុំជាអ្នកដាក់អក្សរដិត)*

**វិធាន ៣៖**

ការដាក់ពន្ធនាគារ ហើយនិងវិធានការដទៃទៀត ដែលបណ្តាលឲ្យជនជាប់ឃុំត្រូវកាត់ផ្តាច់ពីការទាក់ទងជាមួយអ្នកដទៃ គឺអាចធ្វើបាន ក្នុងគោលដៅមិនឲ្យមានការអនុវត្តសិទ្ធិស្វ័យសម្រេច តាមរយៈការដកហូតនូវសេរីភាព។ ដូច្នេះ ក្រៅពីការឃុំឃាំងដោយមានមូលហេតុត្រឹមត្រូវច្បាស់លាស់ ហើយនិងការរក្សាវិន័យក្នុងពន្ធនាគារ របបគ្រប់គ្រងនៅក្នុងពន្ធនាគារមិនត្រូវបង្កើនសេចក្តីទុក្ខសោកឈឺចាប់ទៅលើពួកជនជាប់ឃុំ ដែលកំពុងតែមានការឈឺចាប់នោះទៀតឡើយ។

១០. ដូច្នេះ ទាំងនៅថ្នាក់ជាតិ និងនៅលើឆាកអន្តរជាតិ អត្ថបទច្បាប់យកចិត្តទុកដាក់ដល់ការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ឃុំ។ ជាការពិត ការជាប់ពន្ធនាគារគឺជាទណ្ឌកម្មរួចទៅហើយ និងមិនត្រូវបន្ថែមទម្ងន់ដោយលក្ខខណ្ឌមិនសមស្របនឹងស្ថានភាពសុខភាព ឬភាពងាយរងគ្រោះបំផុតរបស់ជនជាប់ឃុំដែលកំពុងអនុវត្តទោសឡើយ។

## ខ. អំពីសំណើសុំព័ត៌មានចាំបាច់ពាក់ព័ន្ធផ្ទាល់នឹងយុត្តាធិការរបស់តុលាការកំពូល ដោយយោងទៅលើស្ថានភាពបច្ចុប្បន្ន

១១. យោងតាមមាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា តុលាការកំពូល គឺជាតុលាការដែលមានយុត្តាធិការ ទាក់ទិននឹងការលំបាកនានាពាក់ព័ន្ធនឹងការឃុំខ្លួនលោក ខៀវ សំផន ដោយសារតែតុលាការកំពូលជាអ្នកប្រកាសការផ្តន្ទាទោស។ ដោយហេតុថា អ.វ.ត.ក ជិតចប់អាណត្តិ វាជាការសំខាន់ក្នុងការដោះស្រាយការលំបាកដែលកើតឡើងរួចមកហើយ និងត្រូវគិតគូរទុកជាមុនអំពីការលំបាកនាពេលអនាគត ដោយពុំអាចប្រមើលមើលឃើញយន្តការសេសសល់ដែលត្រូវដាក់ឲ្យអនុវត្ត។ ជាការពិត ខណៈដែលមាត្រា ២ នៃកិច្ចព្រមព្រៀងបន្ថែម ឆ្នាំ២០២១ ទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជា ចែងអំពីយន្តការសេសសល់ ដែលមុខងារមួយក្នុងចំណោមនោះគឺតាមដានការប្រព្រឹត្តចំពោះទណ្ឌិត[7] មកទល់នឹងថ្ងៃធ្វើសំណើនេះ គ្មានព័ត៌មានច្បាស់លាស់ណាមួយត្រូវបានផ្តល់ជូនមេធាវីការពារក្តីឡើយ ពាក់ព័ន្ធនឹងមុខងារពិតប្រាកដ និងពេលវេលានៃការអនុវត្តយន្តការនេះ។ ពុំមានអ្វីមួយអាចឲ្យដឹងថា តើក្នុងលក្ខខណ្ឌណាខ្លះ លោក ខៀវ សំផន អាចប្តឹងទៅយន្តការនេះជាបន្ទាន់ ក្នុងករណីជួបប្រទះការលំបាក។

១២. ដូច្នេះ ខណៈពេលកំពុងស្ថិតក្នុងដំណាក់កាលតាក់តែងសំអាងហេតុពេញលេញនៃសាលដីកា វាជាការសំខាន់ដែលតុលាការកំពូល ក្នុងក្របខ័ណ្ឌនៃយុត្តាធិការរបស់ខ្លួន ត្រូវទទួលបានព័ត៌មានដែលអាចឲ្យធានាបានថា លក្ខខណ្ឌត្រូវបានបំពេញ សម្រាប់ការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ក្នុងក្របខ័ណ្ឌច្បាប់។ ជាក់ស្តែង គួរឲ្យសោកស្តាយ រយៈពេលបណ្តោះអាសន្ន រវាងការជូនដំណឹងអំពីសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរ និងដំណើរការពិតប្រាកដនៃយន្តការសេសសល់ បណ្តាលឲ្យមានចន្លោះប្រហោងនៃច្បាប់ និងអលទ្ធភាពជាក់ស្តែងក្នុងការអនុវត្តទោសរបស់លោក ខៀវ សំផន ស្របតាមវិធានជាតិ និងអន្តរជាតិ។

១៣. ម្យ៉ាងវិញទៀត មេធាវីការពារក្តីសូមគូសបញ្ជាក់ថា ភាពមិនច្បាស់លាស់អំពីដំណើរការនៃយន្តការសេសសល់ មិនកម្រិតត្រឹមបញ្ហានៃការតាមដានលក្ខខណ្ឌឃុំឃាំងប៉ុណ្ណោះទេ ថែមទាំងលាតសន្ធឹង

---

[7] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ចុះខែសីហា ឆ្នាំ២០២១ (“កិច្ចព្រមព្រៀងបន្ថែម”) មាត្រា ២-១ *(មុខងារសេសសល់)*។

ដល់សិទ្ធិរបស់ពិរុទ្ធជនទៀតផង ដូចមានចែងក្នុងវិធាន ១១២ នៃវិធានផ្ទៃក្នុង អំពីលទ្ធភាពនៃបណ្តឹងសើរើចំពោះសាលក្រមស្ថាពរ[8]។

១៤. ឆ្លៀតឱកាសនេះ មេធាវីការពារក្តីសូមចង្អុលបង្ហាញជាផ្លូវការថា លោក ខៀវ សំផន បានស្នើសុំសហមេធាវីការពារក្តីទាំងពីររូប គឺលោក គង់ សំអុន និងលោកស្រី Anta GUISSÉ ឲ្យជួយគាត់បន្ទាប់ពីការជូនដំណឹងអំពីសាលដីកា នាពេលខាងមុខ។ ជាក់ស្តែង គាត់នឹងត្រូវការជំនួយ ដើម្បីស្វែងយល់អំពីទិដ្ឋភាពគតិយុត្តិនៃសេចក្តីសម្រេចមួយដ៏ស្មុគស្មាញ ក៏ដូចជាដើម្បីបន្តទទួលបានជំនួយផ្លូវច្បាប់ ចំពោះបញ្ហាផ្សេងៗដែលនឹងអាចកើតមានឡើង ក្នុងអំឡុងពេលនៅសេសសល់នៃការឃុំខ្លួនគាត់។ ទោះបីជាមានភាពស្រពេចស្រពិលជុំវិញយន្តការសេសសល់ក៏ដោយ ក៏មេធាវីទាំងពីររូបបានយល់ព្រមបន្តធ្វើជាតំណាង និងត្រូវមានលទ្ធភាពតំណាងឲ្យគាត់។ ជំនួយនេះមានភាពចាំបាច់ណាស់ ពីព្រោះលោក ខៀវ សំផន ស្ថិតក្នុងស្ថានភាពងាយរងគ្រោះបំផុត។

## II. <u>អំពីការព្រួយបារម្ភស្របច្បាប់របស់មេធាវីការពារក្តី ចំពោះលក្ខខណ្ឌឃុំខ្លួនលោក ខៀវ សំផន</u>

### ក. អំពីស្ថានភាពសុខភាពរបស់លោក ខៀវ សំផន

១៥. កើតនៅខែកក្កដា ឆ្នាំ១៩៣១ លោក ខៀវ សំផន នឹងមានអាយុជាង ៩១ ឆ្នាំ ពេលផ្ទេរគាត់ទៅពន្ធនាគារជាតិ ក្រោយពីតុលាការកំពូលចេញសំអាងហេតុពេញលេញនៃសាលដីកា។ ជារួម តុលាការកំពូល និងភាគី បានតាមដានការវិវត្តនៃការទ្រុឌទ្រោមខាងផ្លូវកាយរបស់លោក ខៀវ សំផន ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។ សវនាការលើកចុងក្រោយបានបង្ហាញថា គាត់មិនអាចដើរ ដោយគ្មានជំនួយនោះឡើយ។

១៦. ខាងផ្នែកវេជ្ជសាស្ត្រ របាយការណ៍គ្រូពេទ្យ ដែលបានធ្វើឡើងក្នុងពេលលោក ខៀវ សំផន សម្រាកនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ រម្លឹកអំពីប្រវត្តិនៃបញ្ហាសុខភាព និងការសម្រាកពេទ្យ ចន្លោះពីឆ្នាំ២០០៧ ដល់ឆ្នាំ២០២២។ ប្រវត្តិនេះត្រូវបានរៀបរាប់លម្អិតដូចខាងក្រោម (របាយការណ៍នេះត្រូវបានគ្រូពេទ្យសរសេរជាភាសាបារាំង ហើយមេធាវីការពារក្តីរៀបរាប់ឡើងវិញ)៖

[8] លទ្ធភាពនៃបណ្តឹងសើរើចំពោះសាលក្រមស្ថាពរក៏មានចែងផងដែរ នៅក្នុងកិច្ចព្រមព្រៀងបន្ថែម ជាមួយនឹងការកែប្រែ និងភាពខុសគ្នាខ្លះៗ ធៀបនឹងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[redacted]

[redacted]

១៧. និយាយឲ្យសាមញ្ញ លោក ខៀវ សំផន មានបញ្ហា [redacted] ម្យ៉ាងវិញទៀត គាត់ [redacted] ខណៈដែលគាត់មានបញ្ហាធ្ងន់ធ្ងរក្នុងការធ្វើចលនារួចទៅហើយ។ [redacted] មានសភាពកាន់តែធ្ងន់ធ្ងរឡើង ក្នុងរយៈពេល

---

9 [redacted]

ប៉ុន្មានខែចុងក្រោយនេះ។ បញ្ហាសុខភាពរ៉ាំរ៉ៃទាំងនេះ ទោះបីជាសព្វថ្ងៃនេះ មានភាពនឹងនរក៏ដោយ ក៏នឹងកើនឡើង តាមវ័យ និងកាន់តែមានសភាពធ្ងន់ធ្ងរឡើង តាមពេលវេលា។ ស្ថានភាពសុខភាពទូទៅ និងវ័យរបស់លោក ខៀវ សំផន មានអាការៈ និងមានផលវិបាលជាក់ស្តែង៖

- លោក ខៀវ សំផន មិនអាចដើរបានដោយខ្លួនឯង៖ គាត់ត្រូវមានដែកច្រត់សម្រាប់ដើរ និងរទេះរុញ។ [redacted] ក៏ទាមទារឲ្យមានជំនួយពិសេសផងដែរ សម្រាប់សកម្មភាពនៃជីវិតប្រចាំថ្ងៃ។

- លោក ខៀវ សំផន ត្រូវអាចទទួលបានការតាមដានសុខភាពជាប្រចាំ ជាពិសេស ការពិនិត្យ [redacted] ប្រចាំថ្ងៃ និងទទួលបានរបបអាហារសមស្រប។

១៨. បើតាមមេធាវីការពារក្តី លោក ខៀវ សំផន នឹងក្លាយជាជនជាប់ឃុំដែលមានវ័យចំណាស់ជាងគេបំផុត នៅក្នុងពន្ធនាគារកម្ពុជា ហើយព័ត៌មានអំពីប្រព័ន្ធពន្ធនាគារដែលទទួលបានបង្ហាញថា គេត្រូវគ្រោងទុកជាចាំបាច់នូវបែបបទឃុំឃាំងពិសេស សម្រាប់ករណីលោក ខៀវ សំផន។

## ខ. អំពីលក្ខខណ្ឌឃុំឃាំងជាទូទៅនៅកម្ពុជា

១៩. មេធាវីការពារក្តីលោក ខៀវ សំផន សូមអះអាងថា ប្រព័ន្ធពន្ធនាគារនៅកម្ពុជា ត្រូវបានបរិហារនៅក្នុងរបាយការណ៍ជាច្រើន អំពីបញ្ហាអនាម័យ ភាពចង្អៀតណែន និងការប្រព្រឹត្តចំពោះអ្នកទោស។ ជាក់ស្តែង នៅក្នុងសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានធ្វើការវិភាគរបាយការណ៍ទៀងទាត់លើកទីបីរបស់កម្ពុជា និងបានគូសបញ្ជាក់ពាក់ព័ន្ធនឹងការឃុំឃាំងដូចខាងក្រោម៖

"ទន្ទឹមនឹងការស្វាគមន៍ចំពោះការចាត់វិធានការ ដើម្បីដោះស្រាយបញ្ហា**ចង្អៀតណែនក្នុងពន្ធនាគារ** គណៈកម្មាធិការនៅតែព្រួយបារម្ភចំពោះព័ត៌មានពាក់ព័ន្ធនឹងការកើនឡើងចំនួនអ្នកទោស នៅក្នុងពន្ធនាគារ តាំងពីពេលចាប់ផ្តើមយុទ្ធនាការប្រឆាំងគ្រឿងញៀន នៅឆ្នាំ២០១៦។ គណៈកម្មាធិការខ្វល់ខ្វាយចំពោះអត្រាផ្ទុក ៣០០% ដែលនាំឲ្យមានការមិនបែងចែករវាងយុវជន និងមនុស្សពេញវ័យ ជនជាប់ចោទ និងទណ្ឌិត។ **គណៈកម្មាធិការបានស្នើសុំការពន្យល់អំពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោស ក្រោយពីមានពាក្យបណ្តឹង ឬអធិការកិច្ច**

> **លើលក្ខខណ្ឌឃុំឃាំង**។ ទោះបីជារាជរដ្ឋាភិបាលមានឆន្ទៈកាត់បន្ថយចំនួនជនជាប់ចោទក៏ដោយ **ក៏អ្នកជំនាញមួយរូបបានសង្កេតឃើញកង្វះវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ** ដោយបានរម្លឹកថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការនៃមធ្យោបាយចុងក្រោយ អនុលោមតាមមាត្រា ៩ នៃកតិកាសញ្ញា"[10]។ *(យើងខ្ញុំជាអ្នកដាក់អក្សរដិត)*

២០. ទន្ទឹមនឹងនេះផងដែរ នៅលើគេហទំព័ររបស់ខ្លួន សមាគមគោលនយោបាយគ្រឿងញៀនអន្តរជាតិ បានទាញចំណាប់អារម្មណ៍ទៅលើអត្ថបទមួយដែលមានចំណងជើងថា៖ "កម្ពុជា៖ ស៊ីរ៉ែនប្រកាសអាសន្នបានរោទិ៍ឡើង ដោយសារតែការដាក់មនុស្សលើសចំណុះនៅតាមពន្ធនាគារ ដោយពុំទទួលបានទឹកគ្រប់គ្រាន់ និងការថែទាំវេជ្ជសាស្ត្រសមស្រប" ដោយគូសបញ្ជាក់ថា ជនជាប់ឃុំក្នុងពន្ធនាគារកម្ពុជា "លើសពី ៣៤៣% នៃចំណុះផ្ទុករបស់ពន្ធនាគារ"៖

> "ការសិក្សារបស់អង្គការសហប្រជាជាតិ ដែលគ្របដណ្ដប់រយៈពេលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២០ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ បានរិះគន់ការខ្វះខាតគ្រែ ទឹកស្អាត និងខ្យល់អាកាសបរិសុទ្ធ នៅក្នុងពន្ធនាគារ ដែលជាបញ្ហាអាទិភាពមួយ ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩។
>
> របាយការណ៍ ដែលបង្ហាញជូននៅទីក្រុងហ្សឺណែវ (ប្រទេសស្វីស) ក្នុងសិក្ខាសាលាស្ដីពីអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬដាក់ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបផ្សេងទៀត លាតត្រដាងថា ពន្ធនាគារកម្ពុជាដាក់ជនជាប់ឃុំ ៣៤៣%នៃចំណុះអតិបរមា។
>
> របាយការណ៍បានសរសេរថា ស្ថានភាពនៅក្នុងពន្ធនាគារមានគ្រោះថ្នាក់ដល់កម្រិតដែលលក្ខខណ្ឌអាចបង្កឱ្យមានការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប យោងតាមអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬដាក់ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបផ្សេងទៀត ដោយសារតែកម្រិតនៃការឈឺចាប់

---

[10] "កម្ពុជា៖ គណៈកម្មាធិការសិទ្ធិមនុស្សកោតសរសើរថា សិទ្ធិដូចមានចែងក្នុងកតិកាសញ្ញាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ ប៉ុន្តែការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិនយោបាយ ទាក់ទាញចំណាប់អារម្មណ៍របស់ខ្លួន ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២" https://www.ohchr.org/fr/press-releases/2022/03/dialogue-cambodia-experts-human-rights-committee-ask-about-freedom។

ខាងផ្លូវចិត្ត និងផ្លូវកាយដែលអ្នកទោសបានទទួលរង។ អ្នកជំនាញអង្គការសហប្រជាជាតិក៏បានចង្អុលបង្ហាញ អំពីការស្លាប់គួរឱ្យសង្ស័យជាបន្តបន្ទាប់ នៅក្នុងពន្ធនាគារ ដែលមិនត្រូវបានរាយការណ៍ ឬស៊ើបអង្កេត”[11]។

លើសពីនេះទៀត ស្ថានភាពនេះត្រូវបានបញ្ជាក់អះអាងដោយមន្ត្រីមួយចំនួន ដូចជា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយបានលើកឡើងអំពី “កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃ ក្នុងការដោះស្រាយបញ្ហាចង្អៀតណែនក្នុងពន្ធនាគារ” ជាពិសេស តាមរយៈការសាកល្បងជាលើកដំបូងនូវការដោះលែងដោយមានលក្ខខណ្ឌ[12]។

២១. ព័ត៌មានអំពីការពិតជាក់ស្តែងនៃការឃុំឃាំងនៅកម្ពុជា ទាមទារជាចាំបាច់នូវការទទួលបានព័ត៌មានអំពីលក្ខខណ្ឌនៃការឃុំខ្លួនលោក ខៀវ សំផន នាពេលអនាគត ដោយសារតែវ័យ និងស្ថានភាពសុខភាពរបស់គាត់។

## III. អំពីព័ត៌មានចាំបាច់ដែលតុលាការកំពូលត្រូវទទួលបាន មុនពេលផ្ទេរខ្លួនលោក ខៀវ សំផន

២២. ដោយមើលឃើញស្ថានភាពវេជ្ជសាស្ត្ររបស់លោក ខៀវ សំផន និងវ័យចាស់ជរារបស់គាត់ មេធាវីការពារក្តីស្នើសុំឱ្យសហព្រះរាជអាជ្ញាផ្តល់ជូនតុលាការកំពូល និងភាគី នូវព័ត៌មានជាក់ច្បាស់អំពីវិធានការចាំបាច់ ដើម្បីផ្ទេរគាត់ទៅពន្ធនាគារជាតិ។ សំណួរបន្ទាន់បំផុត មុនពេលផ្ទេរនេះ មានដូចខាងក្រោម៖

- តើលោក ខៀវ សំផន នឹងត្រូវផ្ទេរទៅកាន់មន្ទីរឃុំឃាំងណាមួយ?
- តើលោក ខៀវ សំផន នឹងអាចបន្តទទួលបានការតាមដានសុខភាព តាមការណែនាំរបស់គ្រូពេទ្យដែលកំពុងព្យាបាលគាត់ ដែរឬទេ?

[11] ដកស្រង់ចេញពីអត្ថបទរបស់ Asia News ចេញផ្សាយថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២៖ https://idpc.net/fr/alerts/2022/04/cambodge-la-sirene-d-alarme-declenchee-en-raison-du-surpeuplement-de-prisons-sans-acces-adequats-a-l-eau-et-a-des-soins-medicaux-adequats?setlang=th។

[12] អត្ថបទរបស់ Fresh News ចេញផ្សាយថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២៖ http://freshnewsasia.com/index.php/en/localnews/250729-2022-07-27-05-37-53.html។

- អាស្រ័យតាមទីកន្លែងឃុំឃាំងដែលបានគ្រោងទុក តើមន្ទីរពេទ្យណានៅជិតបំផុត ប្រសិនបើគ្មាននៅក្នុងបរិវេណពន្ធនាគារនោះ? តើមានមធ្យោបាយអ្វីខ្លះ សម្រាប់ដឹកលោក ខៀវ សំផន ទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យនោះ?

- តើបន្ទប់ឃុំឃាំងដែលបានគ្រោងទុក មានរចនាសម្ព័ន្ធសមស្របនឹងការធ្វើចលនារឹតត្បិតរបស់លោក ខៀវ សំផន ដែរឬទេ (របាទប់សម្រាប់កាន់ដើរទៅបង្គន់ និងនៅក្នុងបន្ទប់ទឹក កន្លែងសម្រាប់ដែកកាន់ដើរ រទេះរុញ កម្រាលមិនរអិលសមស្របដើម្បីចៀសវាងការដួល។ល។)?

- តើមានការរៀបចំពិសេសដែរឬទេ ទាក់ទងនឹងបុគ្គលិកដែលត្រូវផ្តល់ជំនួយដល់លោក ខៀវ សំផន សម្រាប់កាយវិការប្រចាំថ្ងៃ? គួររម្លឹកថា ក្នុងក្របខ័ណ្ឌនៃការរៀបចំ នៅក្នុងមន្ទីរឃុំឃាំងបច្ចុប្បន្ន មនុស្សពីរនាក់ផ្លាស់គ្នាជាប្រចាំថ្ងៃ ដើម្បីជួយដល់គាត់ជាចាំបាច់។

- ដោយសារតែលោក ខៀវ សំផន មានវ័យចាស់ជរា តើមានការរៀបចំអ្វីខ្លះ ដើម្បីជួយសម្រួលដល់ការចូលសួរសុខទុក្ខពីគ្រួសារ ដែលអាចឲ្យបំពេញបន្ថែមរបបអាហារ និងជួយដល់កាយវិការប្រចាំថ្ងៃ? សំណួរនេះមានសារសំខាន់ណាស់ ប្រសិនបើជំនួយបច្ចុប្បន្នទាំងនេះមិនមាននៅកន្លែងឃុំឃាំងថ្មីនោះទេ។

- តើលោកខៀវ សំផន នឹងទទួលបានមធ្យោបាយជាក់ស្តែងអ្វីខ្លះ ដើម្បីបន្តទំនាក់ទំនងជាមួយមេធាវី ក្នុងក្របខ័ណ្ឌនៃការអនុវត្តសិទ្ធិរបស់គាត់ ជាអាទិ៍ អនុលោមតាមវិធាន ១១២ នៃវិធានផ្ទៃក្នុង និងមាត្រា ២ នៃកិច្ចព្រមព្រៀងបន្ថែម?

២៣. ជាការសន្និដ្ឋាន មេធាវីការពារក្តីសូមលើកឡើងជាថ្មីម្តងទៀតថា ខ្លួនមានការព្រួយបារម្ភខ្លាំងចំពោះការប្រមើលមើលឃើញលក្ខខណ្ឌ ដែលខ្លួននឹងអាចរក្សាទំនាក់ទំនងជាមួយលោក ខៀវ សំផន ក្នុងពេលផ្ទេរគាត់ និងពេលក្រោយទៅទៀត និងសូមបញ្ជាក់ថា កេរដំណែលតុលាការរបស់ អ.វ.ត.ក ក៏ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធផងដែរទៅនឹងបែបផែននៃការគោរពតាមបទបញ្ជាផ្ទៃក្នុង និងកិច្ចព្រមព្រៀងបន្ថែម ក្នុងពេលផ្ទេរលោក ខៀវ សំផន និងពេលក្រោយមកទៀត។ ចម្លើយទៅនឹងសំណួរដែលបានចោទសួរទាំងនេះនឹងចូលរួមដល់ការប្រព្រឹត្តទៅដោយរលូននៃដំណើរការទាំងមូល។

## អាស្រ័យហេតុនេះ

២៤. មេធាវីការពារក្ដីលោក ខៀវ សំផន ស្នើសុំតុលាការកំពូល មេត្តាបង្គាប់ឲ្យសហព្រះរាជអាជ្ញាផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងការរៀបចំ សម្រាប់ការផ្ទេរខ្លួនលោក ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងដើម្បីអនុវត្តទោស ក្រោយពេលចេញសំអាងហេតុពេញលេញនៃសាលដីកា ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២២ ជាពិសេស ឆ្លើយតបនឹងសំណួរដូចបានលើកឡើងនៅកថាខណ្ឌ ២២ នៃសំណើនេះ។

| | | |
|---|---|---|
| **មេធាវី គង់ សំអុន**<br><br>**មេធាវី Anta GUISSÉ** | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |